**<u>៨-២-៥ បុណ្យកឋិន</u>**

បុណ្យកឋិនធ្វើឡើងដើម្បីប្រគេនស្បង់ចីវរឬសង្ឃាដីដល់ព្រះសង្ឃដែលគង់នៅចាំវស្សាអស់ត្រីមាស នៅក្នុងវត្តអារាម ឬ នៅជនបទ ណាមួយ កណ្តាលផ្លូវ ។

បុណ្យកឋិនមានតាំងពីពុទ្ធកាលម្ល៉េះ បុណ្យនេះ ប្រារព្ធធ្វើដោយពុទ្ធបរិស័ទ ចាប់ពីថ្ងៃ ១រោច ខែអស្សុជទៅដល់ថ្ងៃ ១៥ កើត ខែកត្តិក។ ក្នុងរយៈ២៩ថ្ងៃនេះ គេអាចធ្វើបុណ្យកឋិននៅថ្ងៃណាមួយក៏បានដែរ។ តែបុណ្យនេះ ប្លែកពីបុណ្យទាំងពួងដោយហេតុ៥យ៉ាង ដូចតទៅនេះ គឺ ៖

១-ប្លែកដោយកាល គឺមិនអាចធ្វើរាល់ថ្ងៃបានទេ។ មួយឆ្នាំ ធ្វើបានតែរវាង ២៩ ថ្ងៃ តាំងពី ១ រោច ខែអស្សុជ ទៅទល់នឹងថ្ងៃ ពេញបូណ៌មីខែកត្តិក ប៉ុណ្ណោះ ។ ហើយមួយវត្ត បានតែម្តង ក្នុង១រដូវ។

២-ប្លែកដោយវត្ថុគឺសំពត់ដែលជា កឋិនវត្ថុ បានតែស្បង់ ឬចីពរ ឬសង្ឃាដី ហើយចំពោះវត្ថុ៣មុខនេះ ព្រះសង្ឃលោកក្រាលគ្រង លោករើសយកតែវត្ថុណាមួយធ្វើជាអង្គឋិន គឺស្រេចលើព្រះទ័យលោក លោកចង់យកស្បង់ជាអង្គកឋិនក៏បាន ចីពរក៏បាន សង្ឃាដីក៏បាន ឲ្យតែវត្ថុនោះៗត្រឹមត្រូវតាមវិនយប្បញ្ញត្តិ ។

៣-ប្លែកដោយអំពើ គឺបុគ្គលអ្នកធ្វើ គប្បីធ្វើឲ្យត្រឹមត្រូវតាមវិនយប្បញ្ញត្តិហើយ ព្រះសង្ឃ គប្បីក្រាលគ្រងឲ្យត្រឹមត្រូវតាមវិនយប្បញ្ញត្តិដែរ ទើបកើតជា កឋិនត្រឹមត្រូវ បានអានិសង្ស ។

៤-ប្លែកដោយអានិសង្ស គឺបុគ្គលអ្នកធ្វើក៏បានអានិសង្ស ព្រះសង្ឃអ្នកទទួលក្រាលគ្រង និងអនុមោទនាក៏បានអានិសង្ស៥យ៉ាង ដូចមានចែងក្នុង វិន័យបិដក ត្រង់កឋិនក្ខន្ធកៈ នោះសព្វគ្រប់ស្រាប់ហើយ។

៥-ប្រែកដោយបដិគ្គាហកៈ(អ្នកទទួល)គឺបានតែភិក្ខុ ក្រៅពីនេះពុំបានហើយភិក្ខុសោត ទៀត លុះណាតែបាននៅចាំវស្សាអស់ ៣ខែ ទើបបាន ។

សូមជម្រាបថាដើមឡើយ ក្នុងបឋមពោធិកាល ភិក្ខុប្រើប្រាស់តែ **បង្សុកូលចីវរ** ពុំទាន់ឲ្យប្រើ **គហបតីចីវរ** នៅឡើយទេ ។

សម័យមួយកាលព្រះសម្មាសម្ពុទ្ធ គង់នៅចាំវស្សានាវត្តជេតពន ជិតដល់ថ្ងៃចូលវស្សាហើយ ភិក្ខុ៣០អង្គ នៅស្រុកបាវា ប្រាថ្នានឹងទៅថ្វាយបង្គំព្រះដ៏មានព្រះភាគ មុនថ្ងៃចូលវស្សា តែទៅមិនទាន់ ក៏ចូលវស្សានៅជនបទមួយ ត្រង់កណ្តាលផ្លូវ។ ដល់បវារណាចេញវស្សាហើយ ទើបនាំគ្នាទៅថ្វាយបង្គំព្រះអង្គ។ ដល់ពេលដែលភិក្ខុទៅនោះ ភ្លៀងច្រើនពេក ភិក្ខុទាំងនោះមាន ស្បង់ចីវរ ទទឹកជោកដោយទឹកភ្លៀង ហើយដោយហេតុចង់ឃើញព្រះភក្ត្រព្រះអង្គឆាប់ៗ ក៏នាំគ្នាចូលទៅថ្វាយបង្គំទាំងស្បង់ចីពរទទឹកនោះ។ ព្រះអង្គទតឃើញដូច្នោះ ក៏ទ្រង់អនុញ្ញាតឲ្យភិក្ខុ ព្រះពុទ្ធសាសនាទទួលសំពត់ កឋិនដែលជា **គហបតីចីវរ** បានតាំងពីពេលនោះមក។ កិច្ចបុណ្យកឋិនដែលខ្មែរយើងតែងធ្វើ ជាប់ជាប្រពៃណីតាំងពីបុរាណកាល មាន ៨ ថ្នាក់ ៖

១-កិច្ចធ្វើសំពត់កឋិន,

២-កិច្ចសុំវត្តធ្វើកឋិន,

៣-កិច្ចផ្សាយដំណឹងបុណ្យកឋិន,

៤-កិច្ចសូត្រមន្តកឋិន និង ទេសនា,

៥-កិច្ចហែកឋិនប្រទក្សិណព្រះវិហារ (វិលស្តាំ)៣ ជុំ,

៦-កិច្ចសូត្រសុទ្ធរកថា ពណ៌នា ពីបុណ្យកឋិន,

៧-កិច្ចវេរសំពត់កឋិននិងបរិក្ខារ ជាបរិវារកឋិន ដោយមាន អាចារ្យ ជាអ្នកនាំមុខ,

*៨-កិច្ចឧទ្ទិសផលរបស់ឧបាសក ឧបាសិកា (យំ កិញ្ចិ… )*

(ចប់បុណ្យកឋិន)

*<u>សង្កេត</u> :*

*បន្ទាប់ពីកិច្ចឧទ្ទិសផលរួចហើយ ព្រះសង្ឃលោករៀបចំធ្វើ ពិធីក្រាលគ្រងកឋិន។ ឧបាសក ឧបាសិកា អាចនៅមើលបាន តែត្រូវអង្គុយឲ្យឆ្ងាយពីព្រះសង្ឃចំនួន ២ហត្ថ ១ចំអាម ពោល គឺចន្លោះពីឧបាសកឧបាសិកាទៅព្រះសង្ឃ ត្រូវមានប្រវែង ១ហត្ថ ១ចំអាម។*

*វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ “ ← “ ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។*